# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៥៥៤ ព្ររ.៣.២៦-៩៧

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ប្រធានតុលាការខេត្ត ក្រុង**

**លោកព្រះរាជអាជ្ញាខេត្ត ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** ស្តីពីការផ្សព្វផ្សាយច្បាប់របស់ទីស្តីការក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបអស់លោកថា បណ្តាឯកសារច្បាប់ដែលក្រសួងបានផ្ញើជូនឱ្យបិទផ្សព្វផ្សាយចំនួនពីរលើក កន្លងមកនេះ គឺដើម្បីឱ្យផ្តល់ទៅថ្នាក់ ឃុំ ភូមិ យកទៅបិទផ្សព្វផ្សាយដល់ប្រជារាស្ត្រនៅមូលដ្ឋានឱ្យបានយល់ជ្រួតជ្រាបអំពីការផ្តន្ទាទោសចំពោះការមិនគោរពច្បាប់ ។ ខ្ញុំបានកត់សម្គាល់ឃើញតុលាការខ្លះយកឯកសារនេះយកទៅចែកឱ្យមន្ទីរទាំងឡាយនៅក្នុងខេត្តរាប់រយសន្លឹក ។ ធ្វើនេះគឺខុសទិសដែលខ្ញុំបានណែនាំហើយ ។ អត្ថបទច្បាប់នេះសំដៅទាញអារម្មណ៍ប្រជាជនសាមញ្ញមុនគេបង្អស់ឱ្យដឹងថាការប្រព្រឹត្តអំពើខុសច្បាប់ត្រូវមានទោស ។ ជាការជួយរាំងក្នុងសតិអារម្មណ៍ និងស្មារតីកុំឱ្យប្រព្រឹត្តខុសច្បាប់ ។

ហេតុដូចនេះ អត្ថបទច្បាប់នេះត្រូវផ្តល់ទៅជូនសាលាឃុំទាំងអស់ ទាំងសាលាឃុំនៅទីរួមខេត្ត ដើម្បីបិទផ្សព្វផ្សាយ ។

ដើម្បីធានាឱ្យសម្រេចទិសដៅនេះបានកម្រិតខ្ពស់ ខ្ញុំសូមលោកប្រធានចាត់ឱ្យក្រឡាបញ្ជីម្នាក់ឬបុគ្គលិកតុលាការណាម្នាក់ទទួលបន្ទុករឿងនេះយកអត្ថបទច្បាប់ទៅជូនអភិបាលស្រុកផ្ទាល់ដៃសុំឱ្យលោកផ្តល់ទៅសាលាឃុំយកទៅបិទក្នុងភូមិទាំងអស់ក្នុងស្រុក។ អ្នកទទួលបន្ទុកនេះតាមដានការផ្សព្វផ្សាយដោយចុះតាមមូលដ្ឋានពិនិត្យមើលតើមានបិទផ្សព្វផ្សាយឬទេ។ បើមានការចាំបាច់អាចសុំការសហការពីមន្ទីរស្រុកមួយនាក់ចុះទៅជាមួយគ្នា ។

ក្រសួងទាមទារប្រសិទ្ធិភាព ក្នុងការបំពេញការងារគ្រប់ជាន់ថ្នាក់ ។

សូមលោករាយការណ៍ជាបន្ទាន់តាមការណែនាំរបស់ខ្ញុំ មកខ្ញុំអំពីលទ្ធផលនៃការបិទអត្ថបទផ្សព្វផ្សាយច្បាប់នេះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្នួន**

ចម្លងជូន
-ទីស្តីកការគណៈរដ្ឋមន្ត្រី
-រដ្ឋសភា(គណៈកម្មការនីតិកម្ម)
-(ឯកសារច្បាប់ភ្ជាប់)